# ពាក្យណែនាំដើម្បីការពារកូនរបស់លោក-អ្នកឲ្យមានសុវត្ថិភាព



ការការពារកូនរបស់យើងតាមអ៊ីនធ័រណេតគឺជាក្តីបារម្ភមួយស្ថិតក្នុងដួងចិត្តរបស់យើងទាំងអស់ជានិច្ចខណៈដែលបច្ចេកទេសវិជ្ជាក្នុងពិភពលោកមានការប្រែប្រួលមិនចេះចប់។

ឥឡូវនេះវាមិនត្រឹមតែអ៊ីនធ័រណេតប៉ុណ្ណោះទេ។ ពត៌មានភ្លាមៗ និងការទាក់ទងគ្នាស្ថិតនៅចុងម្រាមដៃរបស់យើង ដោយការប្រើទូរស័ព្ទដៃ និងឧបករណ៍ប្រើដៃដទៃទៀត។ វាស្ទើរតែមិនគួរជឿបានឡើយថា តើវាលឿនយ៉ាងណាទូរស័ព្ទដៃ ទូរសារ ការផ្ញើសារភ្លាមៗ និង ឥឡូវនេះមានទាំង“ធ្វីត”ផងដែរនោះ បានក្លាយជាវិធីទូទៅនៃការទាក់ទងគ្នាទៅហើយ។ ខណៈដែលបច្ចេកទេសវិជ្ជា និងឥរិយាបថវិវឌ្ឍ យើងត្រូវបង្កើតវិធីសាស្ត្រផ្សេងៗ ដើម្បីធានាថា បុត្រីបុត្រារបស់យើងប្រើប្រាស់នូវ បច្ចេកទេសទាំងនេះដោយមានភាពទទួលខុសត្រូវ និងមានសុវត្ថិភាព។

## ការណែនាំដើម្បីសុវត្ថិភាព

- បើសិនលោក-អ្នកជឿថាកូនរបស់លោក-អ្នកត្រូវការទូរស័ព្ទដៃមួយ លោក-អ្នកគួរតែកុំឲ្យមានប្រដាប់ថតរូប ឬថតវីឌីអូ ឬក៏លទ្ធភាពផ្ញើ ឬទទួលរូបឲ្យសោះ។
- ធ្វើឲ្យមានការប្រើប្រាស់អ៊ីនធ័រណេតជាសកម្មភាពគ្រួសារ។ លៃលកដាក់កុំព្យូទ័រ តូចឬធំ ក្នុងបន្ទប់ទទួលភ្ញៀវរួម ឬក៏កន្លែងណាដែលបើកចំហរជាជាងក្នុងបន្ទប់គេងរបស់កូនលោក-អ្នក។
- ធ្វើឲ្យកូនលោក-អ្នកដឹងថា ពួកគេអាចពិភាក្សាជាមួយលោក-អ្នកពីរឿងអ្វីៗដែលពួកគេបានជួបប្រទះតាមអ៊ីនធ័រណេត ដែលធ្វើឲ្យពួកគេមិនស្ងប់ស្រួលក្នុងចិត្ត។ ចូរចាំថា របៀបដែលលោក-អ្នកនិយាយនឹងជាហេតុផលថាតើពួកគេមានការជឿទុកចិត្តលើលោក-អ្នកឬអត់ទៅថ្ងៃក្រោយ។
- តាមសង្កេតមើលសកម្មភាពកូនរបស់លោក-អ្នកក្នុងអ៊ីនធ័រណេត និងការប្រើប្រាស់ទូរស័ព្ទដៃ ឲ្យដូចដែលលោក-អ្នកដាក់កំរិតឲ្យពួកគេមើលតាមទូរទស្សន៍ ដូចសៀវភៅដែលពួកគេអាន និងភាពយន្តគេទស្សនា។
- ប្រាប់កូនរបស់លោក-អ្នកកុំផ្តល់ពត៌មានផ្ទាល់ខ្លួន ឬឆ្លើយតបទៅគេវិញនៅពេលមានអ្នកណាម្នាក់ចង់ឲ្យរបស់របរដល់ពួកគេដោយមិនចង់បានអ្វីវិញ ដូចជាគ្រឿងកុំព្យូទ័រ ឬក៏អំណោយផ្សេងៗ។
- រំឭកកូនរបស់លោក-អ្នកថា មនុស្សដែលពួកគេជជែកជាមួយ នៅជាមនុស្សចម្លែកដដែល ពីព្រោះលោក-អ្នកមិនអាចឃើញ ឬឮអ្នកទាំងនោះបាន។ វាជាការងាយណាស់សំរាប់មនុស្សចាស់បន្លំខ្លួនធ្វើជាកូនក្មេង។ មិត្តភក្តិ តាមអ៊ីនធ័រណេតក៏នៅជាមនុស្សចម្លែកដដែល។
- រកមើលគេហទំព័រណាដែលមានពត៌មានទាក់ទងទៅនឹងគ្រឿងកុំព្យូទ័រដែលមាតាបិតាអាចតាមសង្កេតមើលកូនបាន។



## អ្វីដែលលោក-អ្នកត្រូវដឹង

*ឧបករណ៍រារាំង:* គ្រឿងកុំព្យូទ័រដែលច្រោះពាក្យក្នុងអ៊ីនធ័រណេត និងរារាំងមិនឲ្យលោក-អ្នកចូលគេហទំព័រអ្នកជ្រើសរើស។

*ក្តារបិទប្រកាស:* កន្លែងដែលអ្នកប្រើប្រាស់អាចផ្សាយដំណឹង។ ភាគច្រើនអ្នកអានអាចទាក់ទងទៅអ្នកប្រកាសបានតាមអ៊ីមែល។

*ខាឆ្ល:* ជាកន្លែងមួយនៅក្នុងគ្រឿងកុំព្យូទ័រដែលប្រដាប់ស្រាវទាញយកពត៌មានដូចជា Internet Explorer រឺ Mozilla Firefox ផ្ទុកពត៌មានពីការចូលទៅមើលគេហទំព័រថ្មីកន្លងទៅថ្មីៗ ដែលធ្វើឲ្យវាមានល្បឿនលឿនពេលចូលទៅម្តងទៀត។

*ជជែក:* គឺជាទម្រង់មួយដែលសេវាកម្មជាច្រើនតាមអ៊ីនធ័រណេត ឬក៏គេហទំព័របានផ្តល់ជូន ដើម្បីឲ្យអ្នកប្រើប្រាស់បាន“ជជែក”ដោយការសរសេរដែលមានអក្សរចេញមកភ្លាមៗ ពីមនុស្សដែលពួកគេកំពុងទាក់ទងជាមួយនៅលើកញ្ចក់។ កម្មវិធីជជែកជាច្រើនអាចអនុញ្ញាតឲ្យអ្នកប្រើប្រាស់ដោះដូររូបថត វីឌីអូ ឬក៏សម្លេងបាន។

*អ៊ីមែល:* ជាសារដែលគេវាយជាអក្សរហើយផ្ញើតាមកុំព្យូទ័រទៅបុគ្គលឬក្រុមមនុស្ស។ អ្នកប្រើប្រាស់អាចភ្ជាប់ឯកសារដែលមានរូបភាព សម្លេង និងវីឌីអូបាន។

*គ្រឿងឧបករណ៍សំរាប់ច្រោះ:* គឺជាគ្រឿងកុំព្យូទ័រអ៊ីនធ័រណេតដែលជ្រើសរើស ហើយវិភាគពាក្យឬ ភាសា។ គ្រឿងខ្លះអនុញ្ញាតឲ្យអ្នកប្រើរារាំងការចូលបាន។

*IM ឬក៏សារភ្លាមៗ:* សារភ្លាមៗ គឺជាពាក្យដែលគេប្រើពេល “ជជែក”តាមកុំព្យូទ័រ។ ប្រូក្រាមជាច្រើនមាន“បញ្ជីភ្លើ” ដែលអ្នកប្រើអាចមើលឃើញអ្នកម្នាក់ទៀត បើសិនជាអ្នកនោះប្រើកុំព្យូទ័រ និងមានពេលជជែក។

*បិទផ្សាយ:* ផ្ញើសារទៅកន្លែងដែលក្រុមមនុស្ស ឬសាធារណៈពិភាក្សាគ្នា។



### ប្រយ័ត្នប្រយែងនឹងសញ្ញាព្រមាន

- កូនរបស់អ្នកប្រញាប់បិទកុំព្យូទ័រ ឬក៏ប្តូរកញ្ចក់ពេលអ្នកដើរចូលក្នុងបន្ទប់
- កូនរបស់លោក-អ្នកទទួលសំបុត្រ ឬទូរស័ព្ទពីអ្នកដែលអ្នកមិនស្គាល់
- កូនរបស់លោក-អ្នកចូលទៅគេហទំព័រដែលមានពត៌មានទាក់ទងការធ្វើគ្រាប់ផ្ទុះ អាវុធ ថ្នាំ ឬក៏សកម្មភាពខុសច្បាប់ផ្សេងៗ។

## ដាក់កំរិត

- ដាក់កំរិតសំរាប់កូនរបស់លោក-អ្នកពេលប្រើអ៊ីនធ័រណេត និងទូរស័ព្ទដៃ។
- ធ្វើការជាមួយកូនរបស់លោក-អ្នកដើម្បីសំរេចថា អ្វីសមរម្យឬមិនសមរម្យ។
- បង្កើតឲ្យមានកំរិតក្នុងការប្រើអ៊ីនធ័រណេតផ្ទាល់ខ្លួនសំរាប់គ្រួសារ។ ត្រូវចាំថាមានសេវាកម្មជាច្រើនផ្តល់អ៊ីម៉ែលដោយមិនគិតថ្លៃ ដូច្នេះអ៊ីម៉ែលប្រចាំគ្រួសារ របស់លោក-អ្នកមិនគួរតែសំរាប់កូនតែម្នាក់ប៉ុណ្ណោះទេ។
- ប្រាប់កូនលោក-អ្នកកុំឲ្យឆ្លើយតបសារណាដែលគំរាមគំហែង ឬក៏អាសអាភាស ហើយដាច់ខាតកុំចុចទៅគេហដ្ឋានបន្តទៀតនៅក្នុងអ៊ីម៉ែល ឬក៏ទទួលឯកសារភ្ជាប់មកជាមួយក្នុងកុំព្យូទ័រពីអ្នកដែលមិនស្គាល់។

## អ្វីដែលលោក-អ្នក និងកូនគួរ *កុំ* ធ្វើ

- ***កុំ***អនុញ្ញាតឲ្យកូនរបស់លោក-អ្នកណាត់ជួបជាមួយអ្នកដែលគេជួបតាមអ៊ីនធ័រណេតដោយគ្មានការអនុញ្ញាតពីលោក-អ្នក។ បើសិនជាការណាត់ជួបត្រូវរៀបចំរួចហើយ ត្រូវឲ្យគេជួបនៅទីសាធារណៈ ហើយទៅជាមួយកូនរបស់លោក-អ្នក។
- ***កុំ***ឲ្យពត៌មានទាក់ទងទៅនឹងកូនរបស់លោក-អ្នក ដូចជាឈ្មោះពេញ អាស័យដ្ឋានផ្ទះ ឈ្មោះសាលា លេខទូរស័ព្ទ អាយុ ឬពត៌មានផ្ទាល់ខ្លួនដទៃទៀត។ ហើយក៏***កុំ***ប្រើឈ្មោះកូន ឬអ៊ីម៉ែលនៅទីសាធារណៈ ឬក៏កន្លែងផ្ទុកឯកសារផ្សេងៗ។
- ***កុំ***បិទរូបថតកូនរបស់លោក-អ្នកនៅតាមកន្លែងពិភាក្សាសាធារណៈ ដែលសាធារណៈជនមានសិទ្ធិចូលទៅបាន។

## អ្វីដែលលោក-អ្នក *អាច* ធ្វើ

- សួរអ្នកផ្តល់សេវាកម្មអ៊ីនធ័រណេត(ISP)ឲ្យលោក-អ្នក ពីគោលការណ៍ឯកជនរបស់គេ ហើយតើគេមានសេវាកម្មច្រោះសំរាប់គ្រួសារដែលមានកូនតូចៗ ដែរឬអត់។ បើមិនមាន រកមើលប្រដាប់ច្រោះនោះដែលលោក-អ្នកអាចទិញដោយតម្លៃថោកល្មម។
- មើលកន្លែងផ្ទុកពត៌មានក្នុងកុំព្យូទ័រ និងប្រវត្តិរបស់វា ឲ្យដឹងថាកន្លែងណាខ្លះកូនលោក-អ្នកបានទៅ។ បើសិនជាកូនលោក-អ្នកសំអាតកន្លែងផ្ទុកពត៌មានញឹកញាប់ សួរនាំមើលតើមានហេតុអ្វី។
- បើសិនជាលោក-អ្នកបានដឹងពីការទាក់ទង ឬការប្រើប្រាស់រូបអាសអាភាសពេលប្រើអ៊ីធ័រណេត ចូរទាក់ទងប៉ូលីសជាបន្ទាន់ ទាក់ទងទៅការិយាល័យរដ្ឋអាជ្ញាតំបន់មីដ្ឋលសេក្ស ឬក៏រាយការណ៍ទៅបណ្តាញឲ្យដំណឹងនៃមជ្ឈមណ្ឌលជាតិសំរាប់កុមារបាត់ខ្លួននិងត្រូវគេកេងយកផលប្រយោជន៍ នៅ www.missingkids.com/cybertip ក៏ (800) 843-5678។

## វាជាការខុសច្បាប់

- ក្នុងការរំខាន ធ្វើបាប ឬក៏គំរាមគំហែងអ្នកណាម្នាក់ដោយប្រើគ្រឿងអេឡិចត្រូនិច
- ក្នុងការផ្ញើរូបមនុស្សស្រាតអស់ ឬស្រាតពាក់កណ្តាលខ្លួនទៅអ្នកដទៃ ឬទៅអនីតិជនក្រោម ១៨ឆ្នាំ
- ក្នុងការប្រើប្រាស់អត្តសញ្ញាណប័ណ្ណអ្នកណាម្នាក់តាមអ៊ីនធឺណេត ឬដោយផ្ទាល់ខ្លួនដោយគ្មានការអនុញ្ញាត
- ក្នុងការថតយកចម្រៀងដោយគ្មានការអនុញ្ញាត

## ការផ្ញើរូបអាសអាភាស

### តើអ្វីទៅហៅថា“ផ្ញើរូបអាសអាភាស”និងហេតុអ្វីបានជាវ×ាមានបញ្ហា?

ពាក្យថា“ផ្ញើរូបអាសអាភាស”សំដៅទៅការផ្ញើរូបថត ឬរូបភាពដទៃទៀតដែលបង្ហាញរូបមនុស្សស្ថិតក្នុងស្ថានភាពអាក្រាតខ្លះ ឬក៏ទាំងស្រុងតាមរយៈសារជាអក្សរ ពីទូរស័ព្ទមួយទៅទូរស័ព្ទមួយទៀត។

បញ្ហានេះកំពុងតែកើតមានឡើងដោយសារតែសិស្សសាលាបានផ្ញើចែកចាយរូបអាក្រាតរបស់ខ្លួន មិត្តរួមថ្នាក់ ឬអ្នកដទៃទៀតតាមរយៈសារជាអក្សរ។ ទំរាំដល់ពេលការិយាល័យរបស់យើងដឹងពីបញ្ហាទាំងនោះ ការការពារកុមារត្រូវបានខូចខាតរួចទៅហើយ។ បានសេចក្តីថា រូបថតត្រូវបានគេចែកចាយពាសពេញ ហើយកុមារនោះបានបាត់បង់នូវការឃុំគ្រងលើការផ្ញើនោះ។ ហេតុនេះហើយបានជាការអប់រំ និងការក-ារពារគឺ ជាកត្តាសំខាន់បំផុតក្នុងការណែនាំចំពោះរឿងនេះ។



### តើទង្វើនៃការ“ផ្ញើរូបអាសអាភាស”ជាបទឧក្រិដ្ឋឬ?

អាស្រ័យតាមអាយុ និងរូបភាពរបស់មនុស្សនៅក្នុងរូប ហើយនិងកាលៈទេសៈ ថាតើរូបនោះបានមកដោយវិធីណា ហើយនិងការចែកចាយរូបនោះ សកម្មភាពនៃការផ្ញើរូបអាសអាភាសអាចបង្ករឲ្យល្មើសច្បាប់របស់រដ្ឋពាក់ព័ន្ធទៅនឹងច្បាប់ក្មេងអាក្រាត។

---

សំរាប់ព័តមានបន្ថែម ឬក៏ស្នើសុំឲ្យមានការបណ្តុះបណ្តាលផ្នែកសុវត្ថិភាពប្រើប្រាស់អ៊ីនធ័រណេតក្នុងសហគមន៍របស់លោក-អ្នក
សូមមេត្តាទាក់ទងទៅ
ការិយាល័យរដ្ឋអាជ្ញាតំបន់មីដ្តលសេក្ស៍ តាមលេខ
@
781.897.6800 ឬ 781-897-8300

## ទូរស័ព្ទដៃនិងការប្រើអ៊ីធ័រណេតដោយសុត្ថិភាព

បន្តការនិយាយជាមួយកូនរបស់លោក-អ្នក និងបង្កើតនូវការបើកចំហរក្នុងការទាក់ទងគ្នា។ ពន្យល់ឲ្យបានច្បាស់ទៅកូនរបស់លោក-អ្នកនូវលទ្ធផលអវិជ្ជមាននៃការផ្ញើរូបអាក្រាតរបស់ខ្លួនគេផ្ទាល់ ឬរបស់អ្នកដទៃ។ វាជាការសំខាន់ណាស់ក្នុងការបញ្ជាក់នូវការយល់ដឹងថា នៅពេលដែល-ពួកគេ បានផ្ញើរូបហើយ ពួកគេនឹងបាត់បង់នូវការឃុំគ្រងលើរូបជារៀងរហូត និង គ្មានឱកាសនឹងបានមកវិញទេ។

នៅពេលដែលលោក-អ្នកទិញទូរស័ព្ទដៃឲ្យកូន ត្រូវធ្វើឲ្យកូននោះដឹងថាពួកគេយល់នូវអ្វីដែលលោក-អ្នកដាក់កំរិតឲ្យក្នុងការប្រើប្រាស់ ហើយអ្នកនិងពិនិត្យមើលព័តមាននិងរូបថតក្នុងទូរស័ព្ទរបស់គេម្តងម្កាល។ ពួកគេអាចជំទាស់ ប៉ុន្តែលោក-អ្នកអាចពន្យល់ថា នេះមិនមែនជាការដាក់ទណ្ឌកម្មទេ វាគឺជាការយកចិត្តទុកដាក់ និងការពារពួកគេ។

ឆ្លៀតទទួលផលប្រយោជន៍ពីកម្មវិធីអប់រំដែលគេបង្រៀនតាមសាលា និងក្រុមអ្នកអនុវត្តច្បាប់ជិតខាង ក្នុងសហគមន៍លោក-អ្នក។ ទាំងនេះវានឹងជួយឲ្យលោក-អ្នកនិយាយជាមួយកូនៗ អំពីបញ្ហាទាំងនេះ។

### ចាប់ពីថ្ងៃទី១ ខែតុលា ឆ្នាំ២០១០ វាជាការខុសច្បាប់

- ចំពោះបុគ្គលណាម្នាក់សរសេរ ផ្ញើ ឬអានសារជាលាយល័ក្ខណ៍អក្សរខណៈដែលកំពុងបើកបររថយន្ត ទោះបីរថយន្តនោះកំពុងតែឈប់ក៏ដោយ
- ចំពោះអ្នកបើកបរក្រោមអាយុ១៨ឆ្នាំណា ប្រើប្រាស់ទូរស័ព្ទដៃ ទោះបីទូរស័ព្ទនោះមានឧបករណ៍មិនចាំបាច់ប្រើដៃ ខណៈដែលគេកំពុងតែបើកបររថយន្ត

ការបោះពុម្ពផ្សាយនេះឧបត្ថម្ភដោថវិកាពី
សម្ពន្ធភាពកុមាររដ្ឋម៉ាស្សាជូសេត្ស៍ ជាសាខារបស់រដ្ឋ
ចេញពីសម្ពន្ធភាពកុមារជាតិ

តាមរយៈមជ្ឈមណ្ឌលគាំទ្រកុមារតំបន់មីដ្តលសេក្ស៍
www.middlesexcac.com




# ការណែនាំដើម្បីសុវត្ថិភាព សំរាប់មាតាបិតា

មេធាវីតំណាងរដ្ឋអាជ្ញាតំបន់មីដ្តលសេក្ស៍
Gerry Leone
15 Commonwealth Avenue, Woburn, MA 01801
(781) 897-8300
@
www.middlesexda.com